៤. ភូមិខ្សាច់ក្រហម ឃុំជីខក្រោម ស្រុកស្រែអំបិល

៥. ភូមិតាបែន ឃុំជីខក្រោម ស្រុកស្រែអំបិល

៦. ភូមិចំបក់ ឃុំជីខក្រោម ស្រុកស្រែអំបិល

មានកម្មវត្ថុ: បង្កើតសហគមន៍នេសាទ តំបន់ឆ្នេរសមុទ្រកោះខ្យង ដើម្បីថែរក្សា ការពារ អភិរក្ស ធនធានជលផល ។

ជំពូកទី២
លក្ខខណ្ឌនៃការសំចូលជាសមាជិក ភាពជ្ញកិច្ច និងសិទ្ធិរបស់សមាជិក

ប្រការ៣

ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងចង់ចូលជាសមាជិកសហគមន៍នេសាទ មានសិទ្ធិដាក់សូមចូលដោយស្ម័គ្រ និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម:

- មានលំនៅដ្ឋាននៅបណ្តាលភូមិនៃសគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី១៨ឆ្នាំឡើង

ប្រការ៤

សមាជិកសហគមន៍នេសាទដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ៣ ខាងលើមានសិទ្ធិ:

- ចូលរួមប្រជុំមហាសន្និបាទ និងបោះឆ្នោតស្មើរភាពគ្នា
- បោះឆ្នោត និងឈរឈ្មោះជាបេក្ខជននៃគណៈកម្មការសហគមន៍នេសាទ ស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ
- ទទួលពត៌មានអំពីស្ថានភាពសេដ្ឋកិច្ច សង្គមរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ

- ស្នើឲ្យមានការកោះប្រជុំមហាសន្និបាទវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការស្នើសុំពីសមាជិក យ៉ាងតិច មួយភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់
- ធ្វើនេសាទជាលក្ខណៈគ្រួសារស្របតាមច្បាប់ស្តីពីជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធវិស័យជលផល
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្តឹងតវ៉ា ឬផ្តល់ពត៌មានអំពីបាតុភាពទាំងឡាយណា ដែលប៉ះពាល់ដល់ប្រយោជន៍របស់សហគមន៍ ទៅសមត្ថកិច្ចរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ
- ទទួលការគាំទ្រពីមជ្ឈដ្ឋានដ្ឋាននានាដើម្បីជលប្រយោជន៍របស់សហគមន៍ ។

សមាជិកសហគមន៍នេសាទ ត្រូវទទួលខុសត្រូវរាល់សកម្មភាពរាងៗខ្លួន និងរួមគ្នាចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវ ផ្នែកព្រហ្មទណ្ឌឡើយ។ សមាជិកសហគមន៍នេសាទចំនួន មួយភាគដប់(១/១០) ឡើងទៅអាចស្នើសុំអោយប្រធានគណៈកម្មការសហគមន៍បញ្ជូលបញ្ហាមួយចំនួន ទៅក្នុងរបៀបវារៈ នៃកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទសាមីហើយចំនួនសមាជិក សហគមន៍នេសាទដែលបានស្នើសុំខាងលើនេះអាចចាត់តំណាងចំនួន៣នាក់ ចូលរួមប្រជុំដើម្បីចោតសួរគណៈកម្មការសហគមន៍នេសាទ នៅបញ្ហាទាំងឡាយណាដែលទាក់ទងនឹងចំនួនដែលបានស្នើឡើងនោះ ។

ប្រការ៥

សមាជិកសហគមន៍នេសាទមានកាតព្វកិច្ច និងភារៈកិច្ចដូចខាងក្រោម:

- អនុវត្តន៍តាមបទបញ្ញត្តិនៃច្បាស់ស្តីពីជលផល
- អនុវត្តន៍តាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/ ២៤០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- អនុវត្តអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍ និង លិខិបទដ្ឋានផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ
- អនុវត្តន៍តាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- អនុវត្តន៍តាមសេចក្តីសម្រេចរបស់មហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ
- បង់ប្រាក់សមាជិកភាពចំនួន ១,០០០រៀល តាមការសម្រេចរបស់មហាសន្និបាត នៅពេលដែលដាក់ពាក្យសុំចូលជាសមាជិសហគមន៍នេសាទ
- បង់ប្រាក់ភាគទានប្រចាំឆ្នាំចំនួន ២,៥០០រៀល តាមការសម្រេចរបស់មហាសន្និបាត
- ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទ ដើម្បីជលប្រយោជន៍ និងការរីចំរើនរបស់សហគមន៍នេសាទ
- ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផល ក្នុងសហគមន៍នេសាទ
- ចូលឃ្លាំមើល ទប់ស្កាត់ និងរាយការណ៍រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍ ។

ជំពូកទី៣

លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិក

ប្រការ៦

សមាជិកសហគមន៍នេសាទមានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ:

- ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្ស
- ការផ្លាស់ប្តូរទីលំនៅ ចេញពីកន្លែងនេសាទសហគមន៍
- សាមីខ្លួនទទួលមរណៈភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថានប័នមានសមត្ថកិច្ច។

ប្រការ៧

សមាជិកសហគមន៍អាចត្រូវបណ្តេញចេញពីសមាជិកភាពក្នុងលក្ខខណ្ឌដូចខាងក្រោម:

- ការមិនបង់ភាគទានចំនួន៣លើកជាប់ៗគ្នា
- សាមីខ្លួនត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធធានាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម
- ការធ្វើអោយប៉ះពាលខ្លះដល់ផលប្រយោជន៍ដល់សហគមន៍នេសាទឬសមាជិកសហគមន៍នេសាទដទៃទៀត
- សាមីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុង ក្នុងសហគមន៍នេសាទនេះ។

ជំពូកទី៤

រៀបរបបកាន់បញ្ជី និងឯកសារនានា

ប្រការ៨

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី:

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការជាតិ និងអង្គការ មិនមែនរដ្ឋាភិបាល
- សំណងខូចខាតធនធានជលផលក្នុងកន្លែងនេសាទសហគមន៍
- ចំនួលស្របច្បាប់ផ្សេងៗទៀត

ប្រការ៩

រាល់ការចំណាយថវិកា សហគមន៍ត្រូងអនុវត្តន៍ដូចតទៅ:

- ការចំណាយពី ០០រៀល ដល់ ២០០,០០០រៀល ត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ
- ការចំណាយពី ២០០,១០០រៀល ដល់ ៤,០០០,០០០រៀល ត្រូវសម្រេចដោយគណៈកម្មការសហគមន៍សាទ
- ការចំណាយពី៤,០០០,១០០រៀលឡើងទៅ ត្រូវសម្រេចដោយមហាសន្និបាត។

ប្រការ១០ ការបែងចែកប្រាក់ដែលបានមកពីការជាកពិន័យឬសំណងខូចខាតធនធានក្នុងសហគមន៍

- ក្នុងករណីសងការខូចខាតធនធានសហគមន៍ត្រឹម ១០០,០០០ រៀលចុះក្រោម

-១០% ចូលទៅបេឡារបស់សហគមន៍

-១០% សម្រាប់មូលនិធិសង្គ្រោះបន្ទាន់ និង គាំទ្រទុនដល់សមាជិកសហគមន៍(ក្រុមកែច្នៃផលនេសាទផ្សេងៗ)

-៨០% សំរាប់កំលាំងចុះទៅបង្ក្រាប ដើម្បីជាការលើកទឹកចិត្ត និង មធ្យោបាយធ្វើដំណើរ

➢ **ក្នុងករណីពិន័យលើសពី ១០០,០០០ រៀល**

-៦០% បង់ចូលថវិការដ្ឋ

-៣៥% សំរាប់កំលាំងចុះបង្ក្រាបដើម្បីជាការលើកទឹកចិត្ត និងមធ្យោបាយធ្វើដំណើរ

-៣% សម្រាប់ចូលទៅបេឡាសហគមន៍

-២% សម្រាប់ជាមូលនិធិសង្គ្រោះបន្ទាន់ និង គាំទ្រទុនដល់សមាជិកសហគមន៍(ក្រុមកែច្នៃផលនេសាទផ្សេងៗ)

➢ **វិភាគទាន់ពីអ្នកមិនមែនជាសមាជិក និង អ្នកប្រមូលទិញផលនេសាទក្នុងសហគមន៍**

- ក្នុងករណីមិនអ្នកនេសាទមិនមែនជាសមាជិសហគមន៍នេសាទ ត្រូវបង់វិភាគទាន់ប្រចាំឆ្នាំ ១០០,០០០រៀលក្នុង១ឆ្នាំ ចូលក្នុងសហគមន៍ ដោយធ្វើការនេសាទស្របតាមលក្ខន្តិក:របស់សហគមន៍នេសាទ
- ចំពោះអ្នកប្រមូលទិញផលនេសាទក្នុងសហគមន៍ (សមាជិកនិងមិនសមាជិក) ត្រូវបង់វិភាគទាន់ ៥០,០០០រៀលក្នុង១ឆ្នាំដោយធ្វើការប្រមូលទិញស្របតាមលក្ខន្តិក:របស់សហគមន៍នេសាទ

ប្រការ១១

សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារ និងរៀបចំអោយមានបញ្ជី:

- ចំណូល ចំណាយថវិកា សារពើភណ្ឌ
- សមាជិកសហគមន៍នេសាទ
- កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ
- កំណត់ហេតុប្រជុំគណ:កម្មការសហគមន៍នេសាទ
- ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

ប្រការ១២

ការគ្រប់គ្រង និងប្រើប្រាស់ថវិកា:

- ការគ្រប់គ្រងថវិកា ត្រូវមានការកាន់បញ្ជីគណនេយ្យ
- ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកបេឡារបស់សហគមន៍នេសាទ
- រាល់ថវិកាចំណាយត្រូវមានរបាយការណ៍ទូទាត់ ដោយមានសក្ខីបត្រ និងចុះបញ្ជីអោយបានត្រឹមត្រូវ
- ថវិកាដែលត្រូវចំណាយ គឺសម្រាប់តែបម្រើអោយការងារគ្រប់គ្រង អភិរក្ស ការអភិវឌ្ឍន៍សហគមន៍នេសាទ

ជំពូក៥

គណៈកម្មការសហគមន៍នេសាទ

ប្រការ១៣ រនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង



ប្រការ១៤

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធាន និងសមាជិក ។ គណៈកម្មការសហគមន៍នេសាទ ត្រូវបានបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការ ១រូប និងសមាជិកទទួលបន្ទុកហិរញ្ញិក១រូប និង ត្រូវពិភាក្សាបែងចែកការកិច្ចសមាជិកផ្សេង១ទៀត តាមជាក់ស្តែង ។

ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវ ដឹកនាំ និងគ្រប់គ្រងសហគមន៍សហគមន៍នេសាទទាំងមូល ។ អនុប្រធានគណៈកម្មការសហគមន៍នេសាទ ជាជំនួយការអោយប្រធាន ។

ប្រការ១៥

គណៈកម្មការសហគមន៍នេសាទមានអាណត្តិ ៥ ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍ថ្មីដែលត្រូវបានបោះឆ្នោត ជ្រើសរើសក្នុងមហាសន្និបាតអោយចូលកាន់តំណែងជំនួស ។ក្នុងករណីដែលសហគមន៍នេសាទតំណើរការមិនប្រក្រតី ដោយមូលហេតុតំណើរមិនល្អ ឬអ

សមត្ថភាពក្នុងគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍នេសាទចំនួន មួយភាគបី(១/៣)មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញ ដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី ។

ប្រការ១៦

ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាម្នាក់អវត្តមាន ដោយគ្មានមូលហេតុរយៈពេល៦ខែ ឬសុំលាលែងមុនចប់អាណត្តិ បេក្ខជនដែលមានឈ្មោះតាមសម្លេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតកន្លងមក ត្រូវបានជ្រើសរើសតាំងជំនួស ។

ជំពូកទី៦
រៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍

ប្រការ១៧

- គណៈកម្មការសហគមន៍នេសាទត្រូវកំណត់របបប្រជុំអោយបានទៀងទាត់រាល់ខែ។ កិច្ចប្រជុំរបស់គណៈកម្មការនេសាទអាចប្រព្រឹត្តទៅបានលុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចពីរភាគបី(២/៣) នៃសមាជិករបស់គណៈកម្មការទែងមូល។

ប្រការ១៨

ប្រធានគណៈកម្មការជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍អវត្តមាន អនុប្រធានដែលត្រូវបានប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ រាល់ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់។

ប្រធានអង្គប្រជុំត្រូវធានាអោយគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅអោយមានលក្ខណៈប្រជាធិបតេយ្យ មានរបៀបរៀបរយ និងគ្មានការរំខាន។

ប្រធានអង្គប្រជុំអាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិក នោះធ្វើអោយខូចសណ្តាប់ធ្នាប់អង្គប្រជុំ។

ប្រការ១៩

ការសម្រេចលើបញ្ហាណាមួយរបស់សហគមន៍ដូចមានចែងខាងក្រោមនេះ គឺត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ដោយសំលេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទដែលមានវត្តមានក្នុងអង្គប្រជុំ។ ក្នុងករណីដែលមានសំលេងស្មើគ្នាមតិប្រធានអង្គប្រជុំជាឧត្តមានុភាព៖

- សេចក្តីព្រៀងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីព្រៀងគម្រោងថវិកា ចំណូល ចំណាយក្នុងសហគមន៍នេសាទ
- ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស
- ការទទួលពាក្យសុំចូលជាសមាជិកថ្មី
- ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុងដល់សមាជិកសហគមន៍នេសាទ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានគណៈកម្មការសហគមន៍នេសាទត្រូវចាត់អោយធ្វើការជូនដំណឹងដល់សមាជិកសហគមន៍នេសាទអំពីសេក្តីសម្រេចរបស់ខ្លួន។ សេក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហ

គមន៍នេសាទ ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់សហគមន៍នេសាទ ឬសាលាឃុំ សង្កាត់ ក្នុងរយៈពេល៧ ថ្ងៃ យ៉ាងយូរបន្ទាប់ពីការប្រជុំ។

ជំពូកទី ៧
មហាសន្និបាតសហគមន៍នេសាទ

ប្រការ ២០

មហាសន្និបាតសហគមន៍នេសាទជាអង្គប្រជុំកំពូលដើម្បីធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចទាំងឡាយក្នុងនាមសហគមន៍នេសាទ។ មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទត្រូវប្រារព្ធធ្វើឡើង បន្ទាប់ពីក្រុមស្ថាបនិក បានរៀបចំរួចរាល់នៅកិច្ចការទាំងឡាយដែលពាក់ព័ន្ធ នឹងមហាសន្និបាត។

- ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផល តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិកដែលបានដាក់ពាក្យស្នើសុំរួចរាល់មកហើយ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ អនុម័តនៅសេចក្តីសម្រេច និងកិច្ចការសំខាន់ដូចខាងក្រោម:

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- ឈ្មោះសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ។

ប្រការ ២១

មហាសន្និបាតសហគមន៍នេសាទសាមញ្ញត្រូវរៀបចំឡើង ១ឆ្នាំ ម្តង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និង អនុម័តនូវកិច្ចការសំខាន់ៗរបស់សហគមន៍នេសាទ។ ក្នុងករណីចាំបាច់សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំពីសមាជិកសហគមន៍នេសាទមួយភាគបី(១/៣)យ៉ាងតិច ។

ប្រការ២២

គណៈកម្មការសហគមន៍អាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ សមត្ថកិច្ចពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬសម្របសម្រួល ឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍នេសាទ ។

ប្រការ២៣

លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម:

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជាសាធារណៈ និងបិទប្រកាសក្នុងសាលាឃុំសង្កាត់ និងទីស្នាក់ការសហគមន៍នេសាទ
- ការកោះអញ្ជើញសមាជិកសហគមន៍នេសាទឲ្យចូលរួមមហាសន្និបាតសាមញ្ញត្រូវធ្វើឡើង១០ថ្ងៃយ៉ាងតិច មុនថ្ងៃបើកមហាសន្និបាត និង៣ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ
- មហាសន្និបាតសមញ្ញ ឬវិសមញ្ញអាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបានលុះត្រាតែមានវត្តមានលើសពីពាក់កណ្តាលនៃសមាជិកសហគមន៍នេសាទ

- អង្គប្រជុំមហាសន្និបាតដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទ ឬប្រធានអង្គប្រជុំដែលជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកដែលមានវត្តមាន
- មហាសន្និបាតត្រូវអនុម័តជ្រើសលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្តីសម្រេច និងបញ្ជីវត្តមាន
- លេខាកត់ត្រា និងប្រធានអង្គប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុ
- សមាជិកម្នាក់មានសម្លេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្តីសម្រេចរបស់មហាសន្និបាត ត្រូវយកសម្លេងលើសពីពាក់កណ្តាលនៃសមាជិកដែលមានវត្តមាន

ប្រការ២៤

មហាសន្និបាតអនុម័ត:

- សេចក្តីសម្រេចដូចមានចែងក្នុងប្រការ២០កថាខណ្ឌទី៣នៃលក្ខន្តិកៈនេះ
- កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- តួនាទី ភារៈកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- ការសុំលាលែង ឬការបណ្តេញចេញពីសមាសជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
- គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ

ជំពូកទី ៨
ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

ប្រការ២៥

ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ និងចំនួនបេក្ខជនឈរឈ្មោះត្រូវអនុម័តដោយមហាសន្និបាត។

ប្រការ២៦

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ គឺជាភារៈកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតដែលអនុម័តដោយមហាសន្និបាត។ គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាពពី ៣ ទៅ៥ នាក់ ដោយមានប្រធាន អនុប្រធាន និងសមាជិក តាមការកំណត់ជាក់ស្តែងរបស់មហាសន្និបាត និងត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានចំណេះដឹង និងមានសិលធម៌ល្អ។ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវធ្វើការប្តេជ្ញាចិត្តបង្ហាញពីភាពស្មោះត្រង់។

ប្រការ២៧

គណៈកម្មការរៀបចំការបោះឆ្នោតមានភារៈដូចខាងក្រោម:

- ប្រកាសបេក្ខជនឈរឈ្មោះ
- ណែនាំអំពីនិតិវិធីនៃការបោះឆ្នោត
- បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតី ដើម្បីប្រកាសជូនមហាសន្និបាត

- ភារៈកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិបន្ទាប់ពីការប្រកាសលទ្ធផលឆ្នោតចប់ជាស្ថាពរ។

ប្រការ២៨

បេក្ខជនដែលទទួលបានសម្លេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ត្រូវទទួលបានតួនាទីជាអនុប្រធាន ជាសមាជិកគណៈកម្មការសហគមន៍នេសាទ តាមលំដាប់លំដោយ។ ក្នុងករណីបេក្ខជនដែលមានសម្លេងស្មើគ្នាត្រូវជ្រើសរើសស្ត្រីឬបោះឆ្នោតរកអ្នកដែលមានសមត្ថភាព ដោយលើកដៃយកមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិសហគមន៍នេសាទដែលចូលរួម។

ជំពូកទី៩
លក្ខខណ្ឌនៃការរំសាយសហគមន៍ និងនិតិវិធីដោះស្រាយវិវាទ

ប្រការ២៩

ការរំសាយសហគមន៍នេសាទត្រូវធ្វើកតាម:

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថាមានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- សេចក្ដីសម្រេចមហាសន្និបាត

ក្រោយពីរំសាយសហគមន៍នេសាទ ទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាត លើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ។

ប្រការ៣០

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍មានភាពមិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឲ្យបានច្បាស់លាស់អំពីភាពមិនប្រក្រតីនោះភ្លាមមុនពេលប្រកាសលទ្ធផលបោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច ។

ប្រការ៣១

វិវាទទាំងឡាយនៅក្នុងសហគមន៍ត្រូវដោះស្រាយដូចខាងក្រោម:

- គណៈកម្មការសហគមន៍នេសាទត្រូវសម្របសម្រួល និងដោះស្រាយរាល់វិវាទដែលកើតឡើងនៅក្នុងសហគមន៍សាទរបស់ខ្លួន
- ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំនុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផលដើម្បីដោះស្រាយទៅតាមហានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចដែលពាក់ព័ន្ធតាមការចាំបាច់
- ក្នុងករណីដែលបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលផលត្រូវបញ្ជូនសំនុំទៅតុលាការខេត្ត ក្រុងសាមី ដើម្បីដោះស្រាយទៅតាមផ្លូវច្បាប់ ។

ប្រការ៣២

សមាជិកសហគមន៍នេសាទរូបណាដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនោះ ត្រូវទទួលទណ្ឌកម្មពីគណៈកម្មការសហគមន៍ឬមហាសន្និបាតសហគមន៍នេសាទ ទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន ។

ជំពូកទី១០
នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ប្រការ៣៣

ការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវសម្រេចដោយមហាសន្និបាត។ ការលើកសំណើកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ត្រូវធ្វើឡើង ដោយសមាជិកយ៉ាងតិចមួយភាគបី(១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទ១ខែមុនបើកមហាសន្និបាត។ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង នេះអាចកែប្រែបានលុះត្រាតែមានសម្លេងយល់ព្រមលើសពីពាក់កណ្តាលនៃសមាជិកមហាសន្និបាតសហគមន៍នេសាទ។

ជំពូកទី១១
អវសានប្បញ្ញត្តិ

ប្រការ៣៤

លក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូងនៅថ្ងៃ ២៥ ខែសីហា ឆ្នាំ២០១៤ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។

ធ្វើនៅជីខក្រោមថ្ងៃទី ៣០ខែសីហាឆ្នាំ២០១៤

ប្រធានគណៈកម្មការសហគមន៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ឈ្មោះសហគមន៍នេសាទ ៖ កោះខ្យង
ភូមិ ៖ អន់ឆ្នើត
ឃុំ ៖ ជីខក្រោម
ស្រុក ៖ ស្រែអំបិល
ខេត្ត ៖ កោះកុង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ឈ្មោះសហគមន៍នេសាទ ៖ កោះខ្សង
ភូមិ ៖ អន់ផ្អើត
ឃុំ ៖ ជីខក្រោម
ស្រុក ៖ ស្រែអំបិល
ខេត្ត ៖ កោះកុង

បទញ្ញាផ្ទៃក្នុង

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទឲ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និងមានរបៀបរៀបរយ សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម:

ប្រការ១

គណៈកម្មការ និងសមាជិកសហគមន៍នេសាទគ្រប់រូបត្រូវមានការស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុង ជួយស្ថាបនា ព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើអោយមានការរីកចំរើនរបស់សហគមន៍នេសាទ ។

ប្រការ២

គណៈកម្មការសហគមន៍នេសាទ ឬបុគ្គលណាដែលបានកេងប្រវ័ញ្ចធ្វើអោយខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម:

- ចំពោះសមាជិកសហគមន៍នេសាទ ឬបុគ្គលដ៏ទៃទៀតត្រូវសង់ឬទូទាត់ទៅតាមទំហំនៃការខូចខាតជាក់ស្តែង ការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណីមិនព្រមសងត្រូវដាក់ជូន មហាសន្និបាតសម្រេច
- ចំពោះគណៈកម្មការសហគមន៍នេសាទត្រូវសង ឬទូទាត់ការខូចខាតតាមការសម្រេចរបស់មហាសន្និបាត។ ប្រសិនបើនិតិវិធីខាងលើនេះនៅតែមិនអាចដោះស្រាយបាន គឺត្រូវអនុវត្តតាមផ្លូវច្បាប់ និងបទបញ្ជាជាធរមាន។

ប្រការ៣

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទ តាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណីដែលសមាជិកសហគមន៍នេសាទមិនបានចូលរួមប្រជុំចំនួន ៣ដងជាប់គ្នាដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ។

ករណីនៅតែមិនរាងចាល គណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព។

ប្រការ៤

សិទ្ធិដាក់ទាន់កម្ម:

ក. គណៈកម្មការសហគមន៍

- អប់រំណែនាំលើកទី១ លើកទី២ លើកទី៣
- ប្រមានផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ
- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច
- ផ្អាកការនេសាទ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាប់ទៅសមត្ថកិច្ចរដ្ឋបាលជលផល ចំពោះការនេសាទលើសទំហំ ចំនួន និងខុសប្រភេទ ពេលវេលា ទីតាំងតាមការកំណត់នៅក្នុងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងនៅក្នុងកន្លែងសហគមន៍នេសាទ។

ខ. មហាសន្និបាត

- អនុម័តការបណ្តេញចេញដូចមានចែងក្នុងប្រការ៧ នៃលក្ខន្តិកៈសហគមន៍នេសាទ
- សម្រេចលើសំណងការខូចខាតទ្រព្យសម្បត្តិសហគមន៍នេសាទ
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ

- ដាក់ទណ្ឌកម្មដល់សមាជិក ឬបុគ្គលដ៏ទៃដែលគណៈកម្មការមិនអាចដោះស្រាយបាន

ប្រការ៥

សមាជិកសហគមន៍នេសាទគ្រប់រូបត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទអំពីសំភារៈឧបករណ៍នេសាទ ដែលគ្រួសារនីមួយៗប្រើប្រាស់នៅក្នុងកន្លែងសហគមន៍នេសាទ។

ប្រការ៦

សមាជិកសហគមន៍នេសាទអាចប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ នៅក្នុងរដូវបើកនេសាទ ដូចមានចែងខាងក្រោម:

- លបក្តាមមានក្រឡាធំជាង ៦សង់ទីម៉ែត្រ ចំនួន ៣០០លប
- មងក្តាមមានក្រឡាធំជាង ៨សង់ទីម៉ែត្រ ចំនួន ១០០០ម៉ែត្រ
- មងបង្គាមានក្រឡាធំជាង ៣.៨សង់ទីម៉ែត្រ ចំនួន ៥០០ម៉ែត្រ
- លបត្រីក្រឡាធំជាង ៦សង់ទីម៉ែត្រ ចំនួន ៣០លប
- មងត្រីការវាវ ក្រឡាធំជាង ៨សង់ទីម៉ែត្រ ចំនួន៥០០ម៉ែត្រ
- មងត្រីក្បកក្រឡាធំជាង ៤សង់ទីម៉ែត្រ ចំនួន ៥០០ម៉ែត្រ
- សំណាញក្រឡាធំជាង ៣.៨ សង់ទីម៉ែត្រ បណ្តោយមិនលើសពី ៦ម៉ែត្រ
- មងត្រីឆ្ពង់ ក្រឡាធំជាង ១០សង់ទីម៉ែត្រ ចំនួន ៥០០ម៉ែត្រ
- មងត្រីផ្ងោងក្រឡាចាប់ពី ២.៥ សង់ទីម៉ែត្រឡើង ចំនួន ៣០០ម៉ែត្រ
- សន្ទូចរនងមិនលើសពី៥០០ផ្លែ
- លបមឹកមានចំនួនមិនលើសពី ៥០លប
- សន្ទូចបបែលមិនលើសពី១០០០ផ្លែ

ប្រការ៧

សមាជិកសហគមនេសាទ:

- ប្រព្រឹត្តផ្ទុយ ឬរារាំងមិនឲ្យសមាជិកដ៏ទៃអនុវត្តសិទ្ធិ និងកាតព្វកិច្ចដូចក្នុងប្រការ ៥ នៃលក្ខន្តិកៈត្រូវព្យួរសមាជិកភាពដោយគណៈកម្មការសហគមន៍នេសាទ ឬបណ្តេញចេញពីសមាជិកភាពដោយមហាសន្និបាទ
- មិនចូលរួមថែរក្សាការពារធនធានជលផល ឬមិនរាយការណ៍អំពីសកម្មភាពទបល្មើសជលផលត្រូវប្រមានដោយគណៈកម្មការសហគមន៍នេសាទ
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ កាប់ស្តារានព្រៃលិចទឹក ព្រៃកោងកាង ឬបំផ្លាញផ្តាច ឬស្មៅសមុទ្រត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពីជលផល
- ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទ ត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និង រដ្ឋបាលជលផលមានសមត្ថកិច្ច
- អនុវត្តផ្ទុយនឹងបទឬញ្ញត្តិច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងកិច្ចព្រមព្រៀង ឬផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវផ្អាកការនេសាទ ទទួលការប្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីដោះស្រាយតាមច្បាប់។

ប្រការ ៨

ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ អាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងសហគមន៍នេសាទ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ហើយធ្វើកិច្ចសន្យានិងគោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ មិនបានគោរពតាមប្រការនេះគណៈកម្មការសហគមន៍សាទ មានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះ ហើយធ្វើការអប់រំណែនាំ ។

ប្រការ ៩

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូង នៅថ្ងៃទី ២៥ ខែសីហាឆ្នាំ ២០១៨ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណៈកម្មការសហគមន៍សាទ ។

ធ្វើនៅ...ថ្ងៃទី...ខែ...ឆ្នាំ២០...

ប្រធានសហគមន៍នេសាទតំបន់ផ្នែរសមុទ្រកោះខ្យង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្ដីថ្លែងការណ៍
នៃការបង្កើតសហគមន៍នេសាទ

ឈ្មោះសហគមន៍នេសាទ ៖ កោះខ្សាច
ភូមិ ៖ អន់ឆ្នើត
ឃុំ ៖ ជីខក្រោម
ស្រុក ៖ ស្រែអំបិល
ខេត្ត ៖ កោះកុង

សេចក្តីផ្តែចការណ៍

យើងខ្ញុំគណៈកម្មការសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង ដែលបានបង្កើតនៅក្នុងឆ្នាំ២០០៣ ក្រោមការឧបត្ថម្ភបច្ចេកទេសដោយខណ្ឌរដ្ឋបាលជលផលខេត្តកោះកុង និងអង្គការកូម៉ូ អាមេរិចកាំង។

យើងខ្ញុំសូមគោរពជំរាបនាយខណ្ឌរដ្ឋបាលជលផលជ្រាបថា ការផ្តួចផ្តើមបង្កើតសហគមន៍នេះបាន កើតឡើងបន្ទាប់ពីមានភាពអាណាធិបតេយ្យ នៃការនេសាទខុសច្បាប់ និងទំនាស់នេសាទធ្វើអោយ ប្រជាពលរដ្ឋភូមិ ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង បានឯកភាពគ្នាធ្វើសំណើរបង្កើត សហគមន៍នេះឡើង និងស្របតាមគោលនយោបាយកំណែទំរង់វិស័យជលផលរបស់រាជរដ្ឋាភិបាល នៅខែតុលា ឆ្នាំ២០០០ ក្នុងគោលបំណងការពារគ្រប់គ្រង ប្រើប្រាស់ អភិរក្ស អភិវឌ្ឍន៍ ធនធានជលផល និងបរិស្ថានប្រកបដោយចីរភាព ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍មូលដ្ឋាន។

រហូតមកដល់សព្វថ្ងៃ សហគមន៍នេសាទយើងខ្ញុំបានខិតខំប្រឹងប្រែងធ្វើការងារសំខាន់ៗជាច្រើនដូចជាបានផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋអោយបានយល់ដឹងពីសារៈប្រយោជន៍នៃធនធានជលផល និងការគ្រប់គ្រង ថែរក្សា ការពារ។ បានចុះល្បាត និងបង្ក្រាបបទល្មើសជលផល នៅក្នុងដែននេសាទសហគមន៍ ទប់ស្កាត់ការកាប់បំផ្លាញព្រៃកោងកាង ក្រៅពីនេះសហគមន៍បានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការសរសេររបាយការណ៍ និងកំណត់ហេតុ កិច្ចការរដ្ឋបាល យេនឌ័រ ជំនាញសម្របសម្រួល ប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ វិមជ្ឈការ វិសហមជ្ឈការ និងភាពជាដៃគូ។

ទន្ទឹមនឹងនេះសហគមន៍នេសាទយើងខ្ញុំ បានរៀបចំរួចរាល់នូវឯកសារសម្រាប់សហគមន៍នេសាទ ដូចមានចែងក្នុងមាត្រា ៧ ជំពូកទី២ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ដែលរួមមាន បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទីកន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រង។

ដោយផ្អែកលើសមិទ្ធិផលដូចបានរៀបរាប់ខាងលើ និងការសម្រេចរបស់មហាសន្និបាត ដែលបានប្រារព្ធ ធ្វើនៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៤ (អាណត្តិទី៣) យើងខ្ញុំគណៈកម្មការតំណាងអោយសហគមន៍តំបន់ឆ្នេរសមុទ្រកោះខ្យង សូមគោរពជូននាយខណ្ឌរដ្ឋបាលជលផលកោះកុង នូវកិច្ចព្រមព្រៀង កន្លែងនេសាទសហគមន៍ ដែលបានភ្ជាប់ជាមួយនូវបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ននេសាទ និងផែនទីកន្លែងនេសាទសហគមន៍ ដើម្បីពិនិត្យ និងសម្រេច ដោយក្តីអនុគ្រោះ។

យើងខ្ញុំគណៈកម្មការសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង សូមធ្វើការប្តេជ្ញាចិត្ត និងសន្យាថានឹងដឹកនាំក្នុងការគ្រប់គ្រងសហគមន៍នេសាទដោយគោរពទៅតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋាន នានា ដែលទាក់ទងទៅនឹងវិស័យជលផល។

បើសិនជាយើងខ្ញុំបានប្រព្រឹត្តខុស នឹងកិច្ចព្រមព្រៀងខាងលើ យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូមលោកនាយខណ្ឌរដ្ឋបាលជលផល មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ អំពីយើងខ្ញុំ។

ធ្វើនៅជីខក្រោម ថ្ងៃទី...៤...ខែ...០១...ឆ្នាំ២០.....

ប្រធានគណៈកម្មការសហគមន៍នេសាទ

លាង.ធី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតស្នើសុំចុះកិច្ចព្រមព្រៀង
កន្លែងនេសាទសហគមន៍

ឈ្មោះសហគមន៍នេសាទ ៖ កោះខ្យង
ភូមិ ៖ អន់ឆ្នើត
ឃុំ ៖ ជីខក្រោម
ស្រុក ៖ ស្រែអំបិល
ខេត្ត ៖ កោះកុង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ប្រធានសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង
សូមគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកោះកុង

កម្មវត្ថុ: សំណើរសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍តំបន់ឆ្នេរសមុទ្រកោះខ្យង។

យោង: - អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែ មីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។

- សេចក្តីរបស់មហាសន្និបាតសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង ដែលបានប្រារព្ធធ្វើឡើងនៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៤ អាណាតិទី៣។

លិខិតភ្ជាប់: កម្មវិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍តំបន់ឆ្នេរសមុទ្រកោះខ្យង

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោង ខ្ញុំសូមជម្រាបជូនលោកប្រធាន មេត្តាជ្រាបថា: សហគមន៍នេសាទ តំបន់ឆ្នេរសមុទ្រកោះខ្យង បានបង្កើតឡើងនៅឆ្នាំ២០០៣ ដោយស្ម័គ្រចិត្ត និងមានគំនិតផ្តួចផ្តើមបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋភូមិចំបក់ ខ្សាច់ក្រហម តាបែន អន់ឆ្នើត នាពិសី និងព្រៃកជីក ដោយមានការសម្របសម្រួលពីខណ្ឌរដ្ឋបាលជលផលកោះកុង។ សហគមន៍នេសាទមានទីតាំងស្ថិតនៅភូមិអន់ឆ្នើត ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង មានផ្ទៃទំហំ ៦,៤៦២ ហិកតា ដឹកនាំដោយគណៈកម្មការសហគមន៍នេសាទចំនួន **៣២នាក់** មានសមាជិកសរុបចំនួន **៣២២នាក់ ស្រី ៨២នាក់** បន្ទាប់ពីបានបង្កើតរួចមកសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង បានដំណើរការ ការងារយ៉ាងសស្រាក់សស្រាំ ដោយមានការចូលរួមឧបត្ថម្ភគាំទ្រពីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ នៃរដ្ឋបាលជលផល ស្ថាប័នជំនាញ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងអង្គការនានា។ ព្រមជាមួយនោះ គណៈកម្មការសហគមន៍នេសាទបានរៀបចំបញ្ជីឈ្មោះសមាជិក លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទី ផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀង កន្លែងនេសាទសហគមន៍រួចជាស្រេច ហើយនិងគ្រោងរៀបចំកម្មវិធីចុះកិច្ចព្រមព្រៀងសហគមន៍នេសាទ ជាមួយលោកនាយខណ្ឌរដ្ឋបាលជលផលកោះកុង ដែលនឹងប្រព្រឹត្តធ្វើឡើងនាថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១៤ នៅភូមិអន់ឆ្នើត ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង ដោយមានការចូលរួមពីសមាជិកសហគមន៍ អាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាឃុំ សង្កាត់ជាសាក្សី។

សូមភ្ជាប់ជាមួយ:

១. កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
២. ផែនទីកន្លែងនេសាទសហគមន៍មាត្រដ្ឋាន ១/៥០០០០
៣. បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ និងគណៈកម្មការសហគមន៍នេសាទ
៤. លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ
៥. សេចក្តីថ្លែងការណ៍នៃការបង្កើតសហគមន៍នេសាទ

អាស្រ័យហេតុនេះ សូមលោកប្រធាន មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

ធ្វើនៅជីខក្រោម ថ្ងៃទី.4..ខែ.01...ឆ្នាំ២០១7

ប្រធានសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឯកសារផ្សេងៗ

ឈ្មោះសហគមន៍នេសាទ	៖ **ពោះខ្សែង**
ភូមិ	៖ អន់ផ្អើត
ឃុំ	៖ ជីខក្រោម
ស្រុក	៖ ស្រែអំបិល
ខេត្ត	៖ ពោះកុង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខេត្តកោះកុង
ចូល
លេខ: ១៤៦៧
ថ្ងៃទី ១៣ ខែ ភញ្ញា ឆ្នាំ ២០១៧
បញ្ជូនមក.....

ពាក្យស្នើសុំ
ចុះបញ្ជីសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង

សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង។

សូមគោរពជូន

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

គោលបំណង:
- លោកមេឃុំជីខក្រោម
- លោកអភិបាលនៃគណៈអភិបាលស្រុកស្រែអំបិល
- លោកនាយខណ្ឌរដ្ឋបាលជលផលកោះកុង
- លោកនាយអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ
- លោកជំទាវអភិបាលនៃគណៈអភិបាលខេត្តកោះកុង
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

កម្មវត្ថុ: សំណើសុំចុះបញ្ជីសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង ក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

យោង:
- ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២០៤ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពី ការបង្កើតសហគមន៍នេសាទ ។
- អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ២០០៧ ស្តីពី ការគ្រប់គ្រងសហគមន៍នេសាទ ។
- ប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ២០០៧ ស្តីពី គោលការណ៍ណែនាំអំពីសហគមន៍នេសាទ ។

ភ្ជាប់ជាមួយនូវ: បញ្ជីឈ្មោះសមាជិកសហគមន៍ ចំនួន ០១ច្បាប់
- លក្ខន្តិកៈសហគមន៍ ចំនួន ០១ច្បាប់
- សេចក្តីសម្រេចរបស់សាលាឃុំជីខក្រោម ស្តីពីការទទួលស្គាល់សមាសភាពគណៈកម្មការសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង អាណត្តិទី៣ ឆ្នាំ ២០១៤
- ផែនទីដែនគ្រប់គ្រងសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំទាំងអស់គ្នាសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា: ដើម្បីធានាបាននូវការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព និងលើកស្ទួយជីវភាពប្រជាពលរដ្ឋអោយបានល្អប្រសើរឡើង យើងខ្ញុំទាំងអស់គ្នាសូមស្នើសុំចូលរួមគ្រប់គ្រងការពារ និងប្រើប្រាស់ធនធានជលផលក្នុងឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង អោយស្របទៅតាមច្បាប់ស្តីពីជលផល។ ម្យ៉ាងទៀតដើម្បីអោយដំណើរការនៃការគ្រប់គ្រងសហគមន៍នេសាទ ប្រព្រឹត្តទៅបានល្អប្រសើរ និងជោគជ័យ យើងខ្ញុំទាំងអស់គ្នា នឹងសហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នជំនាញពាក់ព័ន្ធ។

អាស្រ័យហេតុនេះសូម **ឯកឧត្តម** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ

ជីខក្រោម ថ្ងៃទី ០៤ ខែ ២ ឆ្នាំ ២០១៧

ប្រធានគណៈកម្មការសហគមន៍នេសាទ

ហត្ថលេខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ២៨១ ប្រក.កសក

ប្រកាស
ស្តីពី
ការចុះបញ្ជីសហគមន៍នេសាទចំនួន០៣ នៅខេត្តព្រៃវែង និងខេត្តកោះកុង

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៦ មាត្រា៤១ មាត្រា៤២ មាត្រា៤៣ និងមាត្រា៩៥ នៃច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.ប ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញប្រកាសលេខ៦៨១ ប្រក.កសក.ប ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យនិងមន្ទីរពិសោធន៍ចំណុះនាយកដ្ឋាននិងវិទ្យាស្ថានក្រោមឱវាទរដ្ឋបាលជលផល
- បានឃើញប្រកាសលេខ៣១៦ ប្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ នេសាទ
- បានឃើញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្មរាជធានី ខេត្ត និងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលឱ្យស្ថិតក្រោមមន្ទីរកសិកម្មរាជធានី ខេត្ត
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

សម្រេច

ប្រការ ១._

ត្រូវបានចុះបញ្ជី និងទទួលស្គាល់ជាផ្លូវការ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនូវសហគមន៍ នេសាទចំនួន០៣ រួមមាន ខេត្តព្រៃវែងមានសហគមន៍នេសាទចំនួន០២ គឺសហគមន៍នេសាទតេជោសំពៅមាស និងសហគមន៍នេសាទសាមគ្គីកំពង់ប្រាំង និងខេត្តកោះកុងមានសហគមន៍នេសាទចំនួន០១ គឺសហគមន៍នេសាទ កោះខ្សាង។ ចំនួនសមាជិក ចំនួនគណៈកម្មការ ទំហំកន្លែងនេសាទសហគមន៍ ឈ្មោះភូមិ ឃុំ ស្រុក ខេត្ត និងនិយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងប្រកាសនេះ។

ប្រការ ២._

ព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗដែលបានកំណត់ក្នុងផែនទី ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងប្រកាសនេះ ត្រូវបានបញ្ជាក់ដោយនាយខណ្ឌរដ្ឋបាលជលផល ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរដែនដី ប្រធានរដ្ឋបាលជលផល និងទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ប្រការ ៣._

ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ដូចមានចែងក្នុងប្រការ២នៃប្រកាសនេះ អាចកែប្រែបានតាមការចាំបាច់ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ប្រការ ៤._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥._

អគ្គលេខាធិការ អគ្គាធិការ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានវិស្វកម្ម កសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពាក់ព័ន្ធ និងប្រធានគណៈកម្មការសហគមន៍នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣ រោច ខែ ភ្ទ្រមាស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៨

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

កន្លែងទទួល៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-ឧទ្ធកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ឧទ្ធកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-រដ្ឋបាលខេត្តពាក់ព័ន្ធ
-ជូចប្រការ ៥
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ៖ ភ្ជាប់ប្រកាសលេខ...២៨២...ប្រ.ត.ត...ចុះថ្ងៃ...អង្គារ...១៣...ខែ...តុលា...ឆ្នាំ...ឆ...ព.ស...២៥៦២
ត្រូវនឹងថ្ងៃទី...១០...ខែ...តុលា...ឆ្នាំ២០១៨

សហគមន៍នេសាទក្នុងខេត្តព្រៃវែង និងខេត្តកោះកុង

ល.រ	ឈ្មោះសហគមន៍នេសាទ	ចំនួនសមាជិក	ចំនួនសមាជិកគណៈកម្មការសហគមន៍	ទំហំផ្ទៃសហគមន៍ (ហិកតា)	ភូមិ	ឃុំ/សង្កាត់	ស្រុក/ក្រុង	Projection :UTM, Everest 1830, Datum : Indian 1960, Zone : 48 N, Unit: Meter	
								(X,Y)	(X,Y)
១. ខេត្តព្រៃវែង									
១	តេជោសំពៅមាស	១៨៨ (១៧)	១១ (១)	២.២២០	-ជ្រៃក្រហឹម -កំពង់ឫស្សី -ត្នោត -ព្រៃមាស -ស្លា -ល្វា	កំពង់ឫស្សី	ពោធិ៍រៀង	A(522049,1283731) B(523226,1282168) C(522134,1280305) D(522198,1279488) E(523548,1279600) F(523531,1278663)	G(524384,1277144) H(524862,1275257) I(522293,1275077) J(520393,1279633) K(520781,1282567)
២	សាមគ្គីកំពង់ប្រាំង	១៨៧ (១១)	១១	៣.៦៣០	-កំពង់ប្រាំង -សំបូរ -ព្រៃកតាវ<ត -ព្រៃកជ្រូក -ពាក់ស្ស -ល្វាកោង	កំពង់ប្រាំង	ពារាំង	A(516071,1288193) B(515734,1287601) C(519016,1285683) D(518534,1280342) E(514028,1277756)	F(513004,1284322) G(513533,1277403) H(514903,1288078) I(515967,1288183)
					-បទសន្ទ្រា -ខ្សុំជើង -ខ្សុំត្បូង	កំពង់ពពិល			

					-ពហ៊ា -តាំងរលាង				
២. ខេត្តកោះកុង									
១	កោះខ្សែង	៣២២ (៨២)	១១ (២)	៦.៤៦២	អន់ផ្ដើត	ជីខក្រោម	ស្រែអំបិល	A(342300,1233907) B(344322,1230928) C(346598,1226875) D(346735,1226102) E(349159,1225055)	F(350619,1225510) G(353720,1224303) H(353912,1223034) I(339991,1223043) J(339518,1224861)

បានឃើញនិងឯកភាព

ថ្ងៃ.អង្គារ.១៣.ណាត..... ខែ.ជ.ណាឆ. ឆ្នាំ.ច.ស.ដ.....ស័ក ព.ស ២.៥.៦.២

រាជធានីភ្នំពេញ ថ្ងៃទី.១០.....ខែ.តុលា...ឆ្នាំ.....២.០.១.៨

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

អេង ជាសាន